**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# លិខិតថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ**ប៉ាង សុខឃី** ត្រូវជាភរិយានៃសពលោក **ម៉ែន ម៉ាលីជា** អតីតអនុប្រធានការិយាល័យសុវត្ថិភាពឧស្សាហកម្ម នៃនាយកដ្ឋានបច្ចេកទេស វិទ្យាសាស្រ្ត និងបច្ចេកវិទ្យា ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមឱនកាយគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងខ្ពង់ខ្ពស់ជាទីបំផុតចំពោះ **ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្រ្តី រដ្ឋមន្រ្តីក្រសួងឧស្សាហកម្ម និងសិប្បកម្ម** ព្រមទាំង**លោកជំទាវ** ឯកឧត្តមរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល និងថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្មទាំងអស់ដែលបានជួយឧបត្ថម្ភដល់គ្រួសារនាងខ្ញុំ ដោយក្តីមេត្តាករុណាប្រកបដោយសទ្ធាជ្រះថ្លាក្នុងការចូលរួមជួយរំលែកទុក្ខចំពោះគ្រួសារនាងខ្ញុំ ។

នាងខ្ញុំព្រមទាំងក្រុមគ្រួសារទាំងអស់គ្នាសូមសំដែងនូវទឹកចិត្តកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅជាទីបំផុតនូវចិត្តសប្បុរសធម៌ជាភាតរភាពប្រកបដោយគុណធម៌ពីសំណាក់ថ្នាក់ដឹកនាំក្រសួងទាំងមូលជាពិសេស **ឯកឧត្តមទេសរដ្ឋមន្រ្តី** និងសូមប្រសិទ្ធពរ បវរមហាប្រសើរ ជូនដល់ ឯកឧត្តម និងលោកជំទាវ ព្រមទាំង បុត្រា និងបុត្រីឱ្យជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

រាជធានីភ្នំពេញ ថ្ងៃទី 18 ខែធ្នូ ឆ្នាំ ២០១៤

**ហត្ថលេខា**

ប៉ាង សុខឃី